June 30, 1998

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

NEC published a regulation to national + international journalists in 1998 election

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ 06. 114/៩៨ គ.ជ.ប

ភ្នំពេញ,ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៨

Fax to Media ...
30/6

**<u>ជំរាបជូន</u>**

លោក ចាងហ្វាងសារពត៌មានទាំងអស់

<u>កម្មវត្ថុ :</u> សំណើសុំក្រើនរំលឹក នូវបទបញ្ជា និង នីតិវិធី ស្តីពីយុទ្ធនាការឃោសនាបោះឆ្នោត និង បទបញ្ជាណែនាំស្តីពីការផ្សព្វផ្សាយ ។

<u>យោង :</u> ស្មារតីអង្គប្រជុំជាមួយតំណាងអង្គការសារពត៌មាននៅថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ១៩៩៨ នៅទីស្តីការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តតាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសង្កេតឃើញថា ថ្មីៗ នេះអង្គការសារព័ត៌មានជាតិបានរួមចំណែកជួយ គ.ជ.ប យ៉ាងច្រើនក្នុងការអនុវត្តន៍បទបញ្ជា ស្តីពីការផ្សព្វផ្សាយ និង នីតិវិធីក្នុងយុទ្ធនាការឃោសនានយោបាយបោះឆ្នោត ។ ទន្ទឹមនេះ ក៏នៅមានសារព័ត៌មានមួយចំនួនបានផ្តៀតឱកាសឃោសនានយោបាយអោយគណបក្សនយោបាយមួយចំនួន ដោយពុំបានគោរពតាមបទបញ្ជានិង នីតិ វិធីស្តីពីយុទ្ធនាការឃោសនាបោះឆ្នោត បទបញ្ជាណែនាំស្តីពីការផ្សព្វផ្សាយ និង ច្បាប់បោះឆ្នោត ដែល គ.ជ.ប បានផ្សព្វផ្សាយរួចហើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សុំធ្វើការក្រើនរំលឹកដល់សារព័ត៌មានមួយ ចំនួនដែលបានរំលោភទៅលើបទបញ្ជា និង នីតិវិធីស្តីពីការផ្សព្វផ្សាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ទោះដោយចេតនា ឬដោយអចេតនាក្តី សូមអោយគោរពតាមបទបញ្ជា និង នីតិវិធីទាំងនោះអោយ បានត្រឹមត្រូវបំផុត ដើម្បីរួមចំណែកធ្វើអោយយុទ្ធនាការឃោសានាបោះឆ្នោតបានប្រព្រឹត្តទៅដោយសេចក្តីស្ងប់ ។

ជាការពិតណាស់ ដំណាក់ការយុទ្ធនាការឃោសនាបោះឆ្នោតជារយៈពេលមួយដែលបរិយាកាសសង្គមត្រូវស្ថិតក្នុងសភាពប្រុងប្រយ័ត្ន ដើម្បីចៀសវាងនូវវិបត្តិទាំងឡាយ ។ ជាបទពិសោធន៍ កន្លងមកការបោះឆ្នោតក្នុងសម័យអ៊ុនតាក់បានកើតមាននូវអំពើហិង្សា ការរំលោភច្បាប់ ការគំរាមកំហែង និងការកាប់សំលាប់ខ្ពស់បំផុតក្នុងរយៈពេលនៃយុទ្ធនាការឃោសនា ។ ក្រៅពីប្រជាជនកម្ពុជាដែលបានទទួល

រងគ្រោះ កំមានបុគ្គលិកស៊ីវិល និងកងកំលាំងប្រដាប់អាវុធរបស់អ៊ុនតាក់ជាច្រើនបានរងគ្រោះថ្នាក់ដល់ជីវិតផងដែរ ។ ដោយមានការព្រួយបារម្ភចំពោះបទពិសោធន៍ដ៏គ្រោះថ្នាក់ទាំងអស់នោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមក្រើនរំលឹកដល់អង្គការសារព័ត៌មានទាំងអស់ សូមអោយពង្រឹងការគោរពបទបញ្ជា និង នីតិវិធីស្តីពីយុទ្ធនាការឃោសនាបោះឆ្នោត បទបញ្ជាណែនាំស្តីពីការផ្សព្វផ្សាយ និង ច្បាប់បោះឆ្នោតអោយបានម៉ត់ចត់ និងត្រឹមត្រូវបំផុត ។

ប្រសិនបើនៅមានការរំលោភ ហើយបំពានទៅលើបទបញ្ជានិង នីតិវិធីស្តីពីការផ្សព្វផ្សាយក្នុងយុទ្ធនាការឃោសនានេះទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងប្រើប្រាស់សិទ្ធិចោទប្រកាន់ចំពោះបទល្មើសទាំងនោះតាមបទបញ្ញត្តិ ដែលមានចែងក្នុងច្បាប់បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសង្ឃឹមថា អង្គការសារព័ត៌មានទាំងអស់ នឹងគោរពតាមសំណូមពរនេះដោយស្មារតី ទទួលខុសត្រូវ និង សហប្រតិបត្តិការខ្ពស់បំផុត ។

សូមលោកចាងហ្វាងសារព័ត៌មានទាំងអស់ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ព្រឹម្ភាញ ១៩៩៨ ~ ២៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ០៦. ១១០៧/៩៨ គ.ជ.ប

រាជធានីភ្នំពេញ , ថ្ងៃទី៣០ ខែ ៦ ឆ្នាំ ១៩៩៨

ជូន Media [illegible]
30/6

## សេចក្តីណែនាំទៅគ្រប់គណៈបក្សនយោបាយ
## ក្នុងដំណាក់កាលយុទ្ធនាការឃោសនា

ដើម្បីអោយដំណើរការបោះឆ្នោត ប្រព្រឹត្តទៅដោយ យុត្តិធម៌ត្រឹមត្រូវ សេរី និង ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងមានលទ្ធិភាពគ្រប់គ្រាន់ ក្នុងការថែរក្សាសុវត្ថិភាព និង សន្តិសុខ ប្រជារាស្ត្រទូទៅ បេក្ខជន និង គណៈបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើសេចក្តីណែនាំដូចតទៅ៖

១- រាល់ការស្នើសុំ ការពារ សន្តិសុខជូន បេក្ខជន វាគ្មិន និង ឥស្សរជននយោបាយរបស់គណៈបក្សទាំងអស់ត្រូវស្នើសុំ មក គ.ជ.ប និង ស្នើរទៅអគ្គនាយកដ្ឋាននគរបាលជាតិដែលមានភារកិច្ចចំបងការពារសុវត្ថិភាព ដោយឈរលើជំហរអព្យាក្រឹត្យ ។

២- រាល់ការស្នើរសុំ កងកម្លាំងនគរបាល ដើម្បីអោយឈរជើង ឬ ប្រចាំការ ដើម្បីការពារទីស្នាក់ការរបស់គណបក្ស ត្រូវស្នើរសុំមក គ.ជ.ប និង អគ្គនាយកដ្ឋាន នគរបាលជាតិ ។

៣- រាល់ការស្នើរសុំ ការពារ រាល់សកម្មភាពឃោសនា របស់គណៈបក្ស ក្នុងដំណាក់កាលយុទ្ធនាការឃោសនា ត្រូវជូនដំណឹង មក គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ យ៉ាងហោចណាស់ ក៏ ៧២ម៉ោងមុនការចាប់ផ្តើម និង ស្នើរជាលាយល័ក្ខអក្សរ ទៅស្ថាប័ននគរបាលតាមទីកន្លែង ដែលត្រូវចុះធ្វើសកម្មភាព យ៉ាងតិចបំផុត ២៤ម៉ោង មុនពេលចាប់ផ្តើម ។

សូមគ្រប់គណៈបក្សនយោបាយ មេត្តា ជ្រាប និង អនុវត្តន៍ នូវសេចក្តីណែនាំ ឱ្យមានប្រសិទ្ធភាព ។

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បណ្ឌិតឧត្តមព្រឹទ្ធាចារ្យ ឆេង ផុន

ចម្លងជូន៖
- ឯ.ឧ ទៀ បាញ់ តំណាង សហរដ្ឋមន្ត្រី
- ឯ.ឧ រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ
- ទាយអគ្គលេខាធិការ
- អគ្គនាយកនគរបាលជាតិ
- គ្រប់គណៈបក្សនយោបាយ
- ឯកសារ-កាលប្បវត្តិ

KINGDOM OF CAMBODIA
NATION-RELIGION-KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

# Press Release

On July 01, 1998 at 8:30 AM, a reception ceremony of twenty seven jeeps and spare parts will be held at the National Election Committee(NEC). The handing over ceremony will be presided over by H.E Mr. Chheng Phon, Chairman of NEC, H.E Mr. Uch Kiman, Secretary of State of the Ministry of Foreign Affairs and International Cooperation, representing the Royal Government of Cambodia and H.E. Mr. Yan Ting Ai, Ambassador Extraodinary and Plenipotentiary of China.

The jeeps and spare parts worth an amount of two million RMB yuan represent a donation from the government of the People's Republic of China to the NEC for the purpose of July 26 elections.

Pnhom Penh, July 01 ,1998.